# សុន្ទរកថាស្តីពីសហប្រតិបត្តិការនិងជំនួយរបស់ប្រទេសអូទ្រីស

លោកប្រធាន

ខ្ញុំមានសេចក្តីរីករាយក្នុងការជម្រាបជូនត្រួស១តាមខ្លឹមសារនៃរបៀបវារៈស្តីពីកិច្ចសហប្រតិបត្តិការនិងជំនួយ ។

ឥទ្ធិពលនៃអាវុធមិនរើសមុខចំពោះប្រជាជនស៊ីវិល នៅតែជាបញ្ហាមួយ ដែលប្រទេសអូទ្រីស ចាត់ទុកថាបញ្ហាដ៏មានសារៈសំខាន់។ យើងព្យាយាមដោះស្រាយបញ្ហានេះតាមផ្លូវច្បាប់ អំពីការពង្រឹងនិយាមនៃច្បាប់ស្តីពីមនុស្សធម៌អន្តរជាតិ និងច្បាប់ស្តីពីសិទ្ធិមនុស្ស។ អនុញ្ញាតឱ្យខ្ញុំជម្រាបជូនថា នៅក្នុងបរិការនេះ សេចក្តីសម្រេចដ៏សំខាន់របស់ក្រុមប្រឹក្សាសន្តិសុខ (១៨៩៤/២០០៩) ស្តីពីការការពារជនស៊ីវិលក្នុងជម្លោះប្រដាប់អាវុធ ដែលការអនុវត្តសេចក្តីសម្រេចនេះគឺជាអាទិភាពមួយក្នុងចំណោមអាទិភាពនានា ក្នុងពេលដែលប្រទេសយើងក្លាយជាសមាជិកមិនអចិន្រ្តៃយ៍របស់ក្រុមប្រឹក្សាសន្តិសុខនេះនៅឆ្នាំ ២០០៩ និង ២០១០ ។

ការការពារជនស៊ីវិលក្នុងជម្លោះប្រដាប់អាវុធ និងការការពារពួកគេពីឥទ្ធិពលនានានៃអាវុធមិនរើសមុខ ដែលត្រូវបានប្រើនៅក្នុងជម្លោះបែបនេះ ទោះជាយ៉ាងណាក៏ដោយ ក៏ជាមូលដ្ឋានគ្រឹះមួយទៀតនៃការងាររបស់យើងនៅក្នុងក្របខណ្ឌនៃអនុសញ្ញាហាមប្រាមគ្រាប់មីនផងដែរ។ យើងមានសេចក្តីរីករាយ និងចំណាប់អារម្មណ៍ ដោយមើលឃើញការបន្តផ្តោតការយកចិត្តទុកដាក់ និងការចូលរួមរបស់រដ្ឋរងគ្រោះពីគ្រាប់មីន និងការតាំងចិត្តដ៏ម៉ឺងម៉ាត់ដើម្បីដោះស្រាយបញ្ហាប្រឈមនៃសកម្មភាពមីនរបស់ខ្លួន។ យើងសូមថ្លែងអំណរគុណចំពោះរដ្ឋភាគីទាំងអស់ ដែលបានធ្វើបច្ចុប្បន្នកម្មអំពីកិច្ចប្រឹងប្រែងរបស់ខ្លួន។

អូទ្រីសបាននិងកំពុងផ្តល់មូលនិធិចំពោះសកម្មភាពមីនចាប់តាំងពីពាក់កណ្តាលទសវត្ស ១៩៩០ នៅប្រទេសជាច្រើន។ ទោះជាយ៉ាងណាក្តី ដូចរដ្ឋជាច្រើនទៀតដែរ កាលពីពេលថ្មី១នេះ យើងចាំបាច់ត្រូវកាត់បន្ថយថវិកាចំពោះជំនួយមនុស្សធម៌ និងសហប្រតិបត្តិការអភិវឌ្ឍន៍ និងកាត់បន្ថយថវិកាពីសកម្មភាពមីនផងដែរ។

ខ្ញុំមានសេចក្តីរីករាយក្នុងការជម្រាបជូនលោក-អ្នកជ្រាបថា ទោះជាយ៉ាងណាក្តី រដ្ឋាភិបាលអូទ្រីសមានលទ្ធភាពផ្តល់ប្រាក់សម្រាប់សកម្មភាពមីននៅឆ្នាំ ២០១២។ តាមពិត ខ្ញុំរីករាយក្នុងការនិយាយថា ទោះបីជាមានវិបត្តិហិរញ្ញវត្ថុទូទៅក្តី យើងនឹងបង្កើនមូលនិធិខ្លះសម្រាប់សកម្មភាពមីនជាក់លាក់ប្រមាណជា ១,៩ លានអឺរ៉ូ ឬ ២,៥ លានដុល្លារអាមេរិក។

គម្រោងខាងក្រោមនេះ ត្រូវបានសម្រេចចិត្តរួចហើយ១ កិច្ចសន្យាសម្រាប់គម្រោងទាំងនោះក៏ត្រូវបានធ្វើរួចហើយ ឬកំពុងរៀបចំ។

នៅអាហ្វ្រិកខាងកើត អូទ្រីសកំពុងផ្ដល់មូលនិធិសម្រាប់គម្រោងអប់រំការកាត់បន្ថយគ្រោះថ្នាក់ដោយសារមីននៅសូម៉ាលី ដោយសហការជាមួយ UNMAS និង UNICEF (៦៥០.០០០ អឺរ៉ូ) និងសម្រាប់ជំនួយជនរងគ្រោះដោយសារមីននៅអេត្យូពី ដោយសហការជាមួយ ICRC (៣៥០.០០០ អឺរ៉ូ)។

នៅអាហ្គានីស្ថាន និងលីបង់ អូទ្រីសបានរួមវិភាគទាន ១៧៥.០០០ អឺរ៉ូ ចំពោះការបោសសំអាតគ្រាប់មីន និងជំនួយជនរងគ្រោះដោយសារមីន។

ជាងនេះទៅទៀត ខ្ញុំមានសេចក្ដីរីករាយសូមប្រកាសថា ខ្ញុំនឹងចុះហត្ថលេខាក្នុងនាមប្រទេសអូទ្រីស លើគោលការណ៍នៃភាពជាដៃគូ ដើម្បីអនុវត្តយុទ្ធសាស្ត្រជាតិស្ដីពីសកម្មភាពមីនជាមួយព្រះរាជាណាចក្រកម្ពុជា ជាមួយនឹងការសន្យាផ្ដល់ប្រាក់ចំនួន ៤០០.០០០ អឺរ៉ូ សម្រាប់រយៈពេលពីរឆ្នាំខាងមុខ។

ទឹកប្រាក់ចំនួន ៣០០.០០០ អឺរ៉ូ នឹងត្រូវបានវិភាជ ដើម្បីគាំទ្រគម្រោងស្ដីពីសកម្មភាពបោសសំអាតមីន និង ១០០.០០០ អឺរ៉ូ សម្រាប់គម្រោងជំនួយជនរងគ្រោះ។

ហេតុនេះ អូទ្រីសនឹងស្ថិតនៅក្នុងស្ថានភាពលើកដំបូង ក្នុងការផ្ដល់ជំនួយទ្វេភាគីចំពោះដំណោះស្រាយនៃមរតកគ្រាប់មីន និងសំណល់ជាតិផ្ទុះពីសង្គ្រាមដ៏ធ្ងន់ធ្ងរ ដែលសាមីប្រទេសសប្បុរសរបស់យើងចាំបាច់ត្រូវតែដោះស្រាយ។

បន្ថែមពីលើនេះ ខ្ញុំមានសេចក្ដីរីករាយសូមជម្រាបបន្ថែមថា មានទឹកប្រាក់ ២០០.០០០ អឺរ៉ូ សម្រាប់ប្រតិបត្តិការបោសសំអាតជាបន្ទាន់ នូវយុទ្ធភណ្ឌមិនទាន់ផ្ទុះនៅលីប៊ី និងទឹកប្រាក់ ១០០.០០០ អឺរ៉ូ សម្រាប់បោសសំអាតយុទ្ធភណ្ឌមិនទាន់ផ្ទុះនៅប្រទេសឡាវ។

គម្រោងទាំងនេះ អមដោយជំនួយដទៃទៀត ជម្រុញឱ្យមានការគាំទ្រលើការដោះមីន ដែលមានទឹកប្រាក់ ១,៩ លាន អឺរ៉ូ ឬ ២,៥ លានដុល្លារអាមេរិក។

លោកប្រធាន អូទ្រីសនៅតែតាំងចិត្តផ្ដល់ជំនួយដល់សកម្មភាពមីននិងធ្វើសហប្រតិបត្តិការក្នុងពេលអនាគត ទោះបីជាស្ថិតក្នុងស្ថានភាពលំបាកផ្នែកថវិកាក៏ដោយ ដើម្បីរួមចំណែកដល់ការប្រឹងប្រែងរួមរបស់យើង។

សូមអរគុណ